# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២២

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ២២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


ទំព័រ

១ – ព្រះបាទអសោកមហារាជ ស្រង់យកអំពីពង្សាវតារលោក . . . . . . . . . ៣

២ – ស្ទឹងគង្គា ជាស្ទឹងស័ក្ដិសិទ្ធ (របស់ឥណ្ឌា) . . . . . . . . . . . . . . ៩

៣ – ការពិនិត្យមើលធម្មជាតិនៃផែនដី ទេមរង្សីរៀបរៀង . . . . . . . . . . . ១២

៤ – ពង្សាវតារក្រុងរោម ស្រង់យកអំពីពោលចារិកផ្សេងៗក្នុងពង្សាវតារលោក(តមក) ១៧

៥ – រឿងព្រេងខ្មែរ “រឿងបុរសម្នាក់ដេកលក់ក្នុងសាលា . . . . . . . . . . ២៤


## រូបក្រៅរឿង


សាមនឿ (ប្រទេសលាវ) ស្រុកបាន-ណា-ម៉ាវ នេះព្រះពុទ្ធរូបដែលកសាងឡើងក្នុង សតវត្សរ៍ទី ១៨ នៃគ្រិស្តសករាជ នៅក្នុងហោព្រះ . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1° L'Empereur Açoka. Extrait de l'histoire universelle........ | 3 |
| 2° La rivière sacrée : le Gange.............................. | 9 |
| 3° Étude sur la nature du sol, par Khemararansī.............. | 12 |
| 4° Histoire de Rome. Extrait de divers documents de l'histoire universelle (suite).................................... | 18 |
| 5° Conte populaire cambodgien inédit : " L'homme qui dort dans un Sàlà "........................ | 24 |


HORS-TEXTE


| | |
|---|---|
| Samneua (Laos), Ban-na-mao — Intérieur du Ho Phra. Bouddha du 18e siècle.................................. | 1 |



សាមនៀ (ប្រទេសលាវ) ស្រុកបាន-ណា-ម៉ាវ នេះព្រះពុទ្ធរូបដែលកសាងឡើងក្នុងសតវត្សរ៍ទី ១៨
នៃគ្រិស្តសករាជ នៅក្នុងហោព្រះ ។

# រឿងព្រះបាទធម្មាសោក

(ស្រង់យកអំពីសៀវភៅ ១ និយាយពីពង្សាវតារលោក លោកអ្នកតែងពង្សាវតាបានចុះរឿងពុទ្ធសាសនា ១ វគ្គ មានសេចក្តីសង្ខេបដូច្នេះ ៗ

កាលពីពុទ្ធសករាជ ២៤៣ ពុទ្ធសាសនាមានសេចក្តីចំរើនឡើងនឹងមានអានុភាពជាត់ធំឡើងច្រើន ៗ មានកុដិស្លឹកតូច ៗ រួមគ្នាជាចំនួនច្រើន សម្រាប់ជាលំនៅនៃព្រះសង្ឃសាវករបស់ព្រះពុទ្ធ ជាទីស្នាក់ជ្រកកោនក្នុងកាលចូលវស្សា (រដូវភ្លៀង) លុះតមកក៏ផ្លាស់ទៅជាមានវត្តដ៏មាំមួនឡើង មានកុដិថ្ម-កុដិឈើឡើងពាសពេញ នៅខណៈនេះហើយ ដែលមានក្បាច់រចនាបែបពុទ្ធសាសនាកើតប្រាកដឡើង ៗ ឯរចនាបែបពុទ្ធសាសនាចាប់ផ្តើមបែកមែកធាងឡើងៈដោយអានុភាពរបស់ប្រទេសទិសខាងលិចមុនគេ ដោយហេតុព្រះបាទអាឡេក្សង់ដ្រ៍ជាអ្នកមានជ័យជំនះ បានវាយទ័ពចូលមកប្រទេសឥណ្ឌាខាងជើងនោះ សឹងមើលឃើញថាប្រទេសនោះមានពួកក្រិកនៅច្រើន នឹងប្រទេសដទៃទៀតក៏មានដែរ ដោយមានផ្លូវចេញចូលទៅមកតាមផ្លូវជើងទឹកតាមអាឡេក្សង់ដ្រ៍ (ក្នុងប្រទេសអេស៊ីប្ត៍) ៗ ប្រទេសគន្ធារៈដែលមានព្រំប្រទល់ខាងជើងឆៀងខាងលិច ជិតស្រុកប៉េសៈវ៉ារ (Peshavar) សព្វថ្ងៃនេះ ជាទីដែលព្រះពុទ្ធសាសនាមានផ្លែផ្កាឡើងច្រើនក្នុងសម័យនោះ តាំងពីពុទ្ធសករាជ ២៤៣ ៗ ទីនេះហើយដែលព្រះពុទ្ធសាសនាបានជួបប្រទះនឹងលោក

របស់ក្រិកនិងឥណ្ឌា តំបន់នេះហើយដែលគេបានឃើញគ្រឿងចម្លាក់រចនា មានរូបមនុស្សសំខាន់ៗក្នុងរឿងព្រេងដែលមានក្នុងសាសនាក្រិក ហើយយកមកធ្វើជាប្រវត្តិសាវតារប៉ែកខាងពុទ្ធសាសនាវិញ ។

ប្រវេណីនិងលទ្ធិសាសនារបស់ព្រះគោតមបានផ្សាយសាយភាយទៅក្នុងប្រទេសឥណ្ឌា ដោយគណាចារ្យ១ក្រុមចេញប្រកាសផ្សាយក្នុងទិសានុទិសតាំងពីពុទ្ធសករាជ២០០ និង៣០០ ប៉ុន្តែត្រូវដឹងថា អនុភាពរបស់លទ្ធិព្រាហ្មណ៍និងរបស់ក្រិកបុរាណ ដែលនៅក្នុងទីនោះៗក៏មាននៅដែរ ។ តែទុកជាដូចម្តេចក៏ដោយ ពុទ្ធសាសនាក៏មានអ្នកស៊ើបអាយុសា-សនាតៗមកជាចំនួនច្រើនមិនខ្វះខាត ទើបគេរក្សាទុកនូវសីលធម៌ដ៏ល្អរបស់ខ្លួន និងសេចក្តីរៀបរយនៃពុទ្ធសាសនាជាន់ដើមរហូតមកបាន ។ ព្រះពុទ្ធសាសនាជាន់ដើមនេះចំរើនលូតលាស់ឡើងដោយមិនបាច់សង្ស័យទេ ចំពោះកិច្ចការជាគ្រឿងចិញ្ចឹមជីវិតរបស់ប្រជាជន តាមកំឡុងដែលពុទ្ធ-សាសនាផ្សាយចូលទៅដល់នោះ ទើបជាហេតុឲ្យពុទ្ធសាសនិកជនជាចំនួនច្រើនក្នុងសម័យជាដំបូងនោះមានចិត្តជ្រះថ្លា ទន់ភ្លន់ មិនគិតតែប្រយោជន៍ខ្លួន មានសេចក្តីចំរើនរុងរឿងមុខគួរឲ្យសរសើរណាស់ ។ ផលអស់នេះកើតឡើងដោយសារចិត្តជឿជាក់ក្នុងសាសនា ទើបនាំឲ្យសាសនារក្សាសេចក្តីចំរើនទុកបានរហូតមក ។ តាំងពីដំបូងមក ព្រះពុទ្ធសាសនានិងលទ្ធិសាសនាព្រាហ្មណ៍មានការទាស់ទែងគ្នា សាសនា

ទាំងពីរមានដំណើរខុសគ្នា គឺដោយហេតុសាសនាព្រាហ្មណ៍គិតតែតទល់ ដើម្បីឲ្យបានចំរើនរុងរឿងសមាគមឥណ្ឌាក្នុងសម័យនោះ ដោយត្រូវការលើកស្ទួយឥទ្ធិពលរបស់ខ្លួនឲ្យបានស្មើនឹងពួកក្សត្រនឹងពួកមេៗ ដែលមិនមែនជាពួកព្រាហ្មណ៍ តែជាពួកអ្នកចម្បាំង ៗ មានអ្នកចម្បាំងម្នាក់ឈ្មោះ ចន្ទ្រគុប្ត-មៅរ្យៈ បានចូលក្នុងពួកក្រិកដែលមានជ័យជំនះឥណ្ឌាប្រាបប្រាមតាមដងទន្លេគង្គា ក៏មានជ័យហូតមក ៗ ពួកក្រិកមិនព្រមឲ្យចន្ទ្រគុប្តៈចូលជាពួកជាមួយផង ទើបចន្ទ្រគុប្តៈរត់ចេញពីពួកក្រិកទៅ ហើយត្រេចរត់ទៅក្នុងជាតិផ្សេងៗ ដែលមាននៅតាមព្រំប្រទល់ទិសខាងជើងឆៀងខាងលិចប្រទេសឥណ្ឌា ហើយបញ្ចុះបញ្ចូលបានមនុស្សជាច្រើន ដល់ក្រោយព្រះបាទអាឡេក្សង់ដ្រ៍ចេញផុតទៅ ចន្ទ្រគុប្តៈក៏ចាប់ផ្ដើមធ្វើចម្បាំងលុកលុយស្រុកបញ្ចាប ហើយមានជ័យជំនះស្រុកទាំងឡាយដែលតាំងនៅតាមដងទន្លេគង្គាកាលពីពុទ្ធសករាជ ២៦២ ហើយរួបរួមជាមហាអាណាចក្រនៅទីផែនដីកបទាំងមូល នៅចំណែកឥណ្ឌាខាងជើង តាំងពីឈូងសមុទ្រខាងលិចទៅដល់ឈូងសមុទ្រខាងកើត ៗ ចន្ទ្រគុប្តៈបានកើតវិវាទគ្នាឡើងនឹងវណ្ណៈពួកព្រាហ្មណ៍ ដោយមិនមានផ្លូវចៀសវាងដោយចន្ទ្រគុប្តៈជាអ្នកកាន់លទ្ធិពុទ្ធសាសនា ដែលជាលទ្ធិមួយទទឹងទាស់នឹងសេចក្ដីចំរើន ខាងការប្រកាន់វណ្ណៈរបស់ពួកព្រាហ្មណ៍ ៗ ទើបបានជួយទំនុកបំរុងគណៈសង្ឃពុទ្ធសាសនា នឹង

ចាត់ចែងការសិក្សារបស់ពុទ្ធសាសនាឲ្យបានចំរើនឡើង ។ ព្រះរាជបុត្រ របស់ទ្រង់ដែលទទួលគ្រងរាជសម្បត្តិជាដំណាតមក គឺព្រះបាទអសោក (ព.ស. ២៧៩ - ៣១៦) ជាមហាក្សត្រមួយអង្គក្នុងពង្សាវតារ ដែល ទ្រង់បានពង្រីកអាណាចក្រតាំងពីអាហ្វហានិស្ថាន ដល់មកមទ្រ័យ ។ ទ្រង់ជាអ្នកមានជ័យមួយ ដែលទ្រង់បានលះបង់ចម្បាំងចេញបាន ក្រោយដែលមានជ័យជំនះហើយ ។ ក្នុងសិលាចារិកមួយ មានសេចក្តី ថា ព្រះអង្គទ្រង់ផ្សាយពង្រីកអាណាចក្រដោយសាសនោបាយ ហើយ ក្នុង ១ ជីវិតរបស់ទ្រង់គិតតែពង្រីកព្រះពុទ្ធសាសនាឲ្យផ្សាយចេញទៅក្នុង លោក ។ ទ្រង់ត្រួតត្រាមហាអាណាចក្ររបស់ទ្រង់ដោយកុសលោបាយ និងសន្តិវិធី ។ ព្រះមហាក្សត្រអង្គនេះ ព្រះអង្គជាពុទ្ធសាសនិកដំបូង មួយអង្គ ដែលទ្រង់ព្រះផ្នួសក្នុងពុទ្ធសាសនាធ្វើជាភិក្ខុក្នុងគណៈសង្ឃ ហើយទ្រង់ប្រគល់កាយថ្វាយព្រះអង្គដើម្បីប្រតិបត្តិតាមអដ្ឋង្គិកមគ្គដោយ ហ្មត់ចត់ ដែលជាមគ្គនាំទៅកាន់ព្រះនិព្វាន ។ ទ្រង់បង្ហាញឲ្យឃើញថា វិធីនេះហើយដែលជាវិធីត្រឹមត្រូវល្អក្នុងសម័យនោះ ទុកជាកិច្ចការដែល មានប្រយោជន៍បំផុត និងជាកុសលធម៌ផង ។ ឯសេចក្តីត្រិះរិះត្រូវ (សម្មាសង្កប្ប) សេចក្តីព្យាយាមត្រូវ (សម្មាវាយាម) ការចិញ្ចឹមជីវិត ត្រូវ (សម្មាអាជីវ) នេះហើយជាកិច្ចការរបស់ទ្រង់ ដូចជាទ្រង់មានព្រះ

រាជានុញ្ញាតឲ្យជីកអណ្ដូងទឹកក្នុងប្រទេសឥណ្ឌា និងដាំដើមឈើមានម្លប់ ។ ទ្រង់ព្រះរាជទានបៀវត្សជារង្វាន់ដល់ពួកខ្ញុំរាជការ ដើម្បីឲ្យគាត់ចែងធ្វើការជាសាធារណកុសល ទ្រង់កសាងមន្ទីរពេទ្យនិងសួនច្បារសាធារណៈ និងសួនច្បារដែលសម្រាប់ដាំតិណជាតិ (ស្មៅ) យកមកប្រើធ្វើជាថ្នាំ ។ ទ្រង់បានតាក់តាំងសភាសេនាបតី ១ ក្រុម ដើម្បីទំនុកបំរុងការពារជនជាតិអ្នកស្រុកនិងជាតិអស្សុរជេត្តិ ។ ទ្រង់ចាត់ឲ្យមានការសិក្សាដល់ពួកស្រីៗ និងទ្រង់ព្យាយាមឲ្យបណ្ដាក្រស្តុំប្រឹងសិក្សារៀនឲ្យមានចំណេះចេះដឹងទូទៅសម្រាប់ជាគ្រឿងចិញ្ចឹមជីវិតរៀងរាល់ខ្លួន ។ ព្រះអង្គទ្រង់បរិច្ចាគទានដ៏ធំសំបើមដល់ព្រះភិក្ខុសង្ឃឲ្យខំខ្មីឃ្មាតសិក្សារៀនសូត្រឲ្យចេះដឹងជ្រៅជ្រះខាងអក្សរសាស្ត្រគ្រប់បែប ។ ទ្រង់ឲ្យឆ្លាក់អក្សរចុះក្នុងសិលាចារឹកជាច្រើន ដាក់ពុទ្ធដំបូន្មានផ្សេងៗរបស់ព្រះពុទ្ធដែលជាពុទ្ធដំបូន្មានងាយៗ សម្រាប់មនុស្សធម្មតា ។ ឥឡូវនេះនៅមានបង្គោលសិលាចារឹកសល់នៅដល់ ៣៥ ផ្ទាំង ។

ទ្រង់បញ្ជូនគណៈធម្មទូតទៅ ដើម្បីប្រកាសផ្សាយដំបូន្មានដ៏វិសេសនិងត្រឹមត្រូវរបស់ព្រះបរមគ្រូ នៅក្នុងប្រទេសកស្មិរៈ ហូតដល់សីឡង់ ។ មានគណៈធម្មទូត ១ ក្រុម មានព្រះរាជបុត្ររបស់ទ្រង់ជាអធិបតី ហើយបាននាំយកមែកពោធិព្រឹក្ស ១ មែកទៅដាំនៅប្រទេសសីឡង់ផង ។

ជាវេលា ២៨ ឆ្នាំ ដែលព្រះបាទអសោកទ្រង់បានធ្វើការងារដែលមានគុណប្រយោជន៍ដើម្បីរម្ងាប់សេចក្ដីក្ដៅក្រហាយរបស់មនុស្សលោក ។ ព្រះនាមរបស់ព្រះបាទអសោកនេះ ជាមហាក្សត្រិយដ៏ទ្រង់យសថ្កុំថ្កើងបំផុតអង្គមួយ នឹងទុកដូចដួងផ្កាយមួយក្នុងពង្សាវតារនៃនានាប្រជាជនក្នុងសម័យនៃយើងសព្វថ្ងៃនេះ ។ ព្រះនាមរបស់ព្រះអង្គជាទីគោរពរាប់អានណាស់ក្នុងប្រទេសទីបេត៍និងប្រទេសជប៉ុន ។

# អំពីស្ទឹងគង្គាដ៏ស័ក្តិសិទ្ធិ

នេះជាស្ទឹងមួយដែលជាទីគោរពដ៏ខ្ពង់ខ្ពស់របស់ឥណ្ឌា ដែលមានគោលទុកក្នុងក្បួនខ្នាតចាស់ៗរបស់ឥណ្ឌា ហើយមានគោលទុកក្នុងមហាកាព្យសំស្ក្រឹតហៅថា មហាភារតៈ សឹងមានរឿងរ៉ាវសំខាន់ៗ ដែលគេបានឆ្លាក់ទុកនៅជញ្ជាំងប្រាសាទនគរវត្ត ។ គេនិយាយអំពីស្ទឹងនេះនឹងបូជនីយស្ថានថា អ្នកដែលបានចុះងូតក្នុងស្ទឹងនេះ សុទ្ធតែជាមនុស្សស្អាតបរិសុទ្ធ ។ ឯគម្ពីរដីកាពុទ្ធសាសនាក៏បានស្គាល់ស្ទឹងនេះច្បាស់ណាស់ដែរ តែមិនបានទុកដាក់ថាជាស្ទឹងស័ក្តិសិទ្ធិទេ ។ ក្នុងរឿងរាមាយណៈថា ព្រះឥសីភាគីរថខំបំពេញវត្តយ៉ាងតឹងរ៉ឹង ដើម្បីឲ្យព្រះគង្គាហូរចុះមកពីស្ថានសួគ៌ ព្រះសិវៈក៏បានស្តេចឡើងទៅលើភ្នំហិមាលយា ដើម្បីសុំព្រះមេគង្គាឲ្យហូរស្រោចមកលើផែនដី ។ ស្ទឹងគង្គានេះមានពាក្យបន់ស្រន់សរសើរជាច្រើនយ៉ាងដូចជា:

"ព្រះគង្គាដ៏ប្រសើរ តែងហូរចុះមកពីស្ថានសួគ៌ ជាព្រះមេគង្គាដែលហូរចុះមកដោយស្ងប់ស្ងាត់ ព្រះគង្គានេះហើយដែលហូរចុះមកពីលើមេឃមកកាន់ផែនដី ហើយធ្លាក់ចុះទៅស្ថាននរក" ដូច្នេះជាដើម ។

មានអាស្រមព្រាហ្មណ៍ជាច្រើនដែលតាំងនៅតាមបណ្ដោយស្ទឹងគង្គា ហើយគេបានសាងរោងគូហាជាច្រើនមានទ្រង់ទ្រាយជានាងទេវធីតា

ហើយក្នុងប្រទេសឥណ្ឌាខាងត្បូងនោះ មានរូបមួយពាក់កណ្ដាលខ្លួនជាមនុស្សស្រី ពាក់កណ្ដាលខ្លួនទៀតជាត្រី (នាងមច្ឆានុ) ពាក់មកុដផង ។ នៅបេងគ័ល មានរូបនាងទេពធីតាគង់លើមករ ព្រះហស្តស្ដាំកាន់ផ្កាឈូក ព្រះហស្តឆ្វេងទ្រង់គ្រឿងភ្លេង តែចួនកាលមានព្រះហស្ត ៤ ក៏មាន ។

ដោយសទ្ធានឹងសេចក្ដីជ្រះថ្លាតាមផ្លូវសាសនាយ៉ាងធំសំបើមនេះហើយ ដែលធ្វើឲ្យស្ទឹងគង្គាប្រកបដោយការសប្បាយរីករាយក្រៃមកក្នុងនៃប្រជាជនឥណ្ឌា ហើយជនឥណ្ឌាគ្រប់ៗថ្នាក់តែងនាំគ្នាមកធ្វើសក្ការបូជាព្រះគង្គា ដែលទុកដូចជាម្ដាយរបស់ជនទាំងពួង ទើបមានពាក្យសូត្របួងសួងព្រះគង្គាហៅព្រះគង្គាថា “ គង្គាមា ” ។ បុណ្យធំៗ ដែលគេតែងធ្វើរាល់ៗឆ្នាំក្នុងខែអាវ្រិលឬខែម៉េនោះ គឺគេធ្វើក្នុងក្រុងពារាណសី ។ ប្រជាជនយកភ្ញីផ្កាទៅធ្វើសក្ការបូជា ពួកសង្ឃព្រាហ្មណ៍ក៏នាំគ្នាសូត្រធម៌តាមទំនៀមព្រាហ្មណ៍ ។

មានអ្នកធុតង្គជាតិចិនម្នាក់ឈ្មោះហៀន - ឆាង កាលពីពុទ្ធសករាជ ១១៧៧ បានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា ដើម្បីសិក្សាព្រះពុទ្ធសាសនា ក៏បាននិយាយអំពីបុណ្យកុសលដែលគេបានទទួលក្នុងការងូតទឹកក្នុងទន្លេគង្គា ។

ក្នុងសព្វថ្ងៃនេះ ពួកព្រាហ្មណ៍ដែលមានសទ្ធាជ្រះថ្លាប្រាថ្នាតែឲ្យបានស្លាប់នៅក្បែរមេគង្គា ទឹងធ្វើការបូជាសពនៅលើឆ្នេរស្ទឹងគង្គានេះ

ដែរ ៗ ប្រសិនបើគេស្លាប់ឆ្ងាយពីស្ទឹងគង្គា គេតែងយកឆ្អឹងទៅបោះបណ្ដែតក្នុងស្ទឹងស័ក្ដិសិទ្ធិ ហើយមានពួកលោកសង្ឃព្រាហ្មណ៍ជាអ្នករៀបចំធ្វើពិធីនេះ ៗ មួយវិញទៀត ទឹកស្ទឹងគង្គានេះ គេតែងដាក់ផ្ញើទៅគ្រប់ៗភាគក្នុងឥណ្ឌា ប្រើជាទឹកពិសេស កំចាត់ខ្មោចបិសាច សម្រាប់ប្រោះបបូរមាត់មនុស្សដែលជិតស្លាប់ សម្រាប់ស្រោចប្រោះព្រំកូនក្រមុំកំលោះក្នុងពិធីអាពាហ៍ពិពាហ៍ ដើម្បីឱ្យបានសេចក្ដីសុខសួស្ដី ៗ

# វិធីត្រួតមើលដី

ពាក្យថា "វិធីត្រួត" ឬពិនិត្យ ជាពាក្យដែលចូលចិត្តយល់បាន ដោយកម្របន្តិច ៗ តែពាក្យថា "ដី" ជាពាក្យដែលចូលចិត្តយល់បានដោយងាយ ៗ ក្នុងទីនេះ យើងនឹងនិយាយពីដីឲ្យស្តាប់ជាមុនសិន រួចសឹមនិយាយពីវិធីត្រួតដែលជាពាក្យលំបាកស្តាប់ជាខាងក្រោយ ៗ

កាលបើយើងពិចារណាឲ្យហ្មត់ចត់ទៅ នឹងឃើញថា ដីនេះជារបស់ជាប់ទាក់ទងនឹងមនុស្សក្នុងលោកគ្រប់រូបយ៉ាងជិតជាបំផុត ដីជារបស់មានប្រយោជន៍ នឹងធ្វើប្រយោជន៍ដល់មនុស្សគ្រប់រូប ហាក់ដូចជាមនុស្សលោកកើតមកពីផ្ទៃនៃផែនដី ដ្បិតមនុស្សលោករស់នៅដោយទឹកដោះរបស់ដី វេលាស្លាប់ទៅក៏ស្លាប់នៅលើដៃនៃដីដែរ ៗ

កាលបើពិនិត្យមើលតាមផ្លូវសេដ្ឋកិច្ច នឹងឃើញថា ដីជាគោគ-សម្ប័ទរបស់ប្រទេសៗ ណាមានដីដីជាតិល្អ ហើយមនុស្សចេះរក្សាដីឲ្យមានរស់ជាតិជានិច្ច នឹងចេះប្រើដីនោះឲ្យមានប្រយោជន៍ពេញទីឡើង ប្រទេសក៏នឹងស្តុកស្តម្ភមាំមួនឡើងលើសប្រទេសឯទៀតៗ មិនខាន ៗ

បើសំឡឹងមើលតាមផ្លូវព្រឹក្សាស្ត្រ ដីនេះជាផ្ទះឬជាស្រុករបស់ពីជគាមនឹងភូតគាមនានាប្រការ មានទំនងដូចគេហស្ថានជាទីជ្រកកោនអាស្រ័យនៃមនុស្សយើងដូច្នោះដែរ ៗ ហេតុនេះ ការជ្រើសរើសដីនឹងវិធីទំនុកបំរុងដីឲ្យមានដីជាតិល្អ សមជាឃ្លាំងអាហារនៃរុក្ខជាតិ តិណជាតិ

វល្លិជាតិ ដើម្បីឲ្យមានផ្លែផ្កាលូតលាស់ល្អ ។ ការដែលអ្នកស្រែចម្ការត្អូញត្អែរថា ខ្លួនដាំឈើផ្កាមិនចេញផ្កា ឬដាំបន្លែមិនល្អ ឬដាំដំណាំមិនមានផ្លែផ្កា ឬមានផ្កាតែមិនកាន់ផ្លែ អស់នេះកើតមកពីដីមិនល្អ ដែលត្រូវតែកែប្រែរៀបចំឡើងជាថ្មី ។

បើសំឡឹងមើលតាមផ្លូវក្សេត្រកម្ម ដីជាធនស្ថាន ១ យ៉ាងធំសំបើមរបស់ធម្មជាតិ ពួកកសិករខ្លះទៅក្នុងលោកតែងតែនាំគ្នាដកយកប្រាក់កាសមកចាយវាយចិញ្ចឹមជីវិតដោយមិនមានកំណត់ចំនួនមនុស្ស ។ អ្នកឯណាមានសតិបញ្ញាឆ្លៀវឆ្លាសនឹងរំឧស្សាហ៍ខ្មីឃ្មាតធ្វើការងារ តែងតែទៅបើកយកប្រាក់ពីផ្ទះបង្គនេះមកចាយបានតាមចិត្ត ប៉ុន្តែបង្គគឺដីនេះមិនព្រមឲ្យអ្នកណាមួយបើកប្រាក់ទេ បើអ្នកនោះមិនព្រមធ្វើការងារសោះ ។

មួយវិញទៀត បើយើងចេះជ្រើសរើសរកដីឲ្យត្រូវនឹងដំណាំ ឬជ្រើសរើសរកដំណាំឲ្យត្រូវនឹងដី ដំណាំក៏រមែងតែចំរើនលូតលាស់ល្អជានិច្ច ។ បើយើងចេះរៀបចំដីឲ្យល្អ ដំណាំក៏នឹងមានផលល្អដល់យើងជានិច្ច ឬចេះតែចំរើនឡើងទៀតមិនខាន ។ បើយើងមិនចេះទំនុកបំរុងរក្សាដីឲ្យមានជីជាតិល្អទេ ដីនេះក៏នឹងរេចរឹលអស់ជីជាតិទៅបន្តិចម្តងៗ ត្រាតែធ្វើការដាំដំណាំមិនកើតក៏មាន ។ ប្រសិនបើដីមានជីជាតិល្អគួរដល់ការដាំដំណាំម្យ៉ាង តែអ្នកដាំមិនយល់ ត្រឡប់ទៅយកដំណាំម្យ៉ាងទៀតមកដាំវិញ ក៏មិនមានផលល្អតាមត្រូវការដែរ ។ ចួនកាលដីនោះមានរសជាតិ

ដូរពេកឬប្រែពេកឬមានលក្ខណៈហាប់ណែនពេក អាកាសទឹងទឹកជ្រាបចូលទៅពុំបានស្រួល ដីបែបនេះបើមិនគិតរកឲ្យបាយកលកែប្រែជាមុនសិនទេ ខំបេះសាំដំណាំអ្វីទៅ មុខតែនឿយកំឡាំងឥតអំពើមិនខាន ។ មានមនុស្សជាច្រើនមកប៉ះទឹងដីបែបនេះ ហើយលើកលែងធ្វើការងារទៅក៏មាន ។

ហេតុនេះការស្គាល់លក្ខណៈរបស់ដីទឹងបេះរិដីប្រតិបត្តិទំនុកបំរុងដីជាកិច្ចសំខាន់បំផុតក្នុងការធ្វើកេ្សត្រកម្ម ។ នានាប្រទេសក្នុងលោកគេខំព្យាយាមសិក្សាស្រាវជ្រាវរិះគិតទឹងល្បងធ្វើជាខ្លាំង ដើម្បីទំនុកបំរុងកេ្សត្រកម្មក្នុងប្រទេសគេឲ្យកាន់តែបំរើនឡើងៗតទៅទៀត ។ កិច្ចសំ-ខាន់ក្នុងការសិក្សារឿងដីនេះ គោងសិក្សាជាច្រើនយ៉ាង ដូចជាសិក្សាឲ្យស្គាល់កំណើតរបស់ដី ថាដីក្នុងតំបន់ណា មានកំណើតមកយ៉ាងណា? ទឹងមានកំណើតកើតមកពីថ្មបែបណា?- ត្រូវសិក្សាឲ្យស្គាល់ផល់លក្ខណៈទឹងគុណភាពរបស់ដីថា ដីនៅតំបន់នេះឬតំបន់នោះជាដីប្រភេទណា ជាពួកដីស្រួយ, ដីស្អិត, មានទឹកហូរជ្រាបចូលបានងាយ ទឹងស្រួលដល់ការប្រើគ្រឿងប្រដាប់បែបណា មានលក្ខណៈដីជាតិត្រឹមណា គួរតាំងគេហស្ថាននៅបានឬទេ ហើយទីដីនោះជាឃ្លាំងអាហាររបស់ដំណាំប្រភេទណាខ្លះ? កាលបើបានជ្រាបសេចក្ដីពិតដូច្នេះហើយ យើងអាចចាត់ចែងដាំដំណាំឲ្យត្រូវសមតាមបំណងមិនខាតកំឡាំង ។ មួយវិញទៀត គោងបេះទំនុកបំរុងដីឲ្យមានជីជាតិជានិច្ចផង ។

កាលបើពិនិត្យមើលតាមផ្លូវក្សេត្រកម្ម ទើបឃើញថា ប្រទេសកម្ពុជារបស់យើងនេះ គួរពជការយកចិត្តទុកដាក់ទំនុកបំរុងដីរបស់ប្រជាជនដែលធ្វើស្រែចម្ការបូរដំណាំទូទៅយ៉ាងម៉ឺងម៉ាត់ ទើបប្រទេសនេះមានសេចក្ដីចំរើនស្ដុកស្ដម្ភឡើងឆាប់ ៗ ស្រូវនឹងពោតជារបរធំបំផុតក្នុងប្រ-ទេសនេះ បាននាំប្រាក់កាសមកចូលស្រុកច្រើនលើសរបរដទៃទៀតទាំងអស់ ៗ របរពោតច្រើនធ្វើនៅតាមមាត់ទន្លេមេគង្គ ស្រូវឡើងទឹកច្រើនធ្វើនៅមាត់ទន្លេសាបនឹងតំបន់លិចទឹកនៅទីដទៃទៀត ព្រោះស្រុកនេះជាស្រុកដែលមានត្រពាំងបឹងបួរទូទៅនៅចំណែកខាងត្បូងនឹងខាងលិច ក៏ប៉ុន្តែនៅតំបន់ដទៃទៀតជាច្រើន ដែលប្រជាជនមិនអាចធ្វើស្រែស្រូវឡើងទឹកបាន គេធ្វើស្រូវពង្រោះ ស្រូវសន្ទូងធម្មតាព្រោះជាទីទួលទឹកទន្លេសាបចូលទៅមិនដល់ គេអាស្រ័យតែទឹកភ្លៀងម្យ៉ាងឬទឹកជន់ពល ដីស្រែប្រភេទក្រោយនេះ ទុកជាជាន់ដំបូងមានជីជាតិល្អយ៉ាងណា ក៏ដោយ លុះអំណើះយូរទៅមុខជារេចរឹលអស់ជីជាតិមិនខាន ៗ ចំណែកឯដីស្រែលិចទឹក ដោយទឹកទន្លេក្ដី ទឹកទន្លេសាបក្ដី ឬដោយទឹកស្ទឹងព្រែកជ្រោះដែលនឹងបង្ហូរល្បប់ចាក់មកលើដីស្រែរាល់ឆ្នាំក្ដី អ្នកធ្វើបែបនេះមិនសូវព្រួយបារម្ភពីជីជាតិប៉ុន្មានទេ តែមានព្រួយនឹងទឹកទន្លេតូច-ធំ នឹងទឹកឡើងឆាប់ពេកឬយឺតពេកប៉ុណ្ណោះ ៗ បណ្ដាដីដែលដាំដំណាំទាំងប៉ុន្មាន តែងតែរេចរឹលទៅថ្ងៃក្រោយមិនខាន គេង

តែក៖ បាយធ្វើឲ្យដីមានជីជាតិជានិច្ច ទើបធ្វើស្រែបានផលល្អរៀងរាល់ឆ្នាំ ៗ ការកែប្រែឬការទំនុកបំរុងដីឲ្យមានជីជាតិជានិច្ចនេះ មើលទៅទំនើងប្រជាជន មិនអាចយល់ដឹងការនេះដោយច្បាស់លាស់ទេ គេនឹងអាស្រ័យក្រសួងកិច្ចការខាងកេ្សត្រកម្មនេះជួយទំនុកបំរុងឬណែនាំពន្យល់ផ្លូវផង ទើបធ្វើការនេះបានសម្រេចដូចបំណង ។

មុនដំបូង យើងយល់ថា គួររកការបោះតាំងប៊ុយរ៉ូបវរវិទ្យា ១ សម្រាប់ពិនិត្យ ឬ ត្រួតមើលដី ហើយចាត់ទៅភ្នាក់ងារផ្នែកនេះឲ្យចេញដើរទៅកាន់ទីតំបន់ផ្សេងៗ រើសយកដីដោយអន្លើៗដែលឃើញថាគួរចាត់ផ្ញើទៅឲ្យពួកប៊ុយរ៉ូពិនិត្យញែកធាតុមើល ដើម្បីឲ្យដឹងស្គាល់ធាតុផ្សេងៗដែលមាននៅក្នុងដីនោះ បើមានកំ្ព ប្តឹ ទន្ទេ ស៊ីង ពែក ក៏ត្រូវពិនិត្យត្រួតមើលដោយហ្មត់ចត់ ហើយចាត់ធ្វើផែនទីទុក ។ ការរៀបចំធ្វើការងារតាមទំនងនេះ នឹងជួយទំនុកបំរុងប្រទេសកម្ពុជាឲ្យបានចំរើនខាងរបរស្រែចម្ការច្បារដំណាំទៅជាប្រាកដពុំខាន ។ ការដែលយល់ថាគ្រាន់តែទៅនាំយកដីពីតំបន់ផ្សេងៗមកពិនិត្យញែកធាតុមើលក្នុងប៊ុយរ៉ូ ក៏អាចប្រាប់បានថា ដីបែបនេះមានជីជាតិច្រើន បែបនេះមានជីជាតិតិច បែបនេះមិនមានជីជាតិ បែបនេះគួរដាំដំណាំនេះ ត្រឹមប៉ុណ្ណោះមិនទាន់ល្មមគ្រប់គ្រាន់ទេ គេនឹងចាត់អ្នកមានវិជ្ជាការស្ទាត់ជំនាញផ្នែកដីនេះចេញទៅត្រួតត្រាហើយរើសយកដីនៅតំបន់នោះមកញែកធាតុពិនិត្យមើល ហើយធ្វើ

ផែនទី ចង្អុលប្រាប់ថា ដីនៅតំបន់នោះ ស្រុកនោះ ឃុំនោះ មានដីជាតិយ៉ាងនេះ គួរដាំដំណាំបែបនេះ ដីនៅតំបន់នោះ គួរកែប្រែដោយវិធីនេះ ដូច្នេះជាដើម ។

តាមដែលពោលមកនេះ ហាក់ដូចជាការងាយស្រួល ប៉ុន្តែដល់ចាប់ធ្វើទៅ ទើបឃើញថាលំបាកហើយយឺតយូរមិនងាយនឹងបានសំរេចតាមចិត្តទេ ទុកជាប្រទេសដែលមានផ្លូវគមនាគមល្អ មានផែនទីមានប៊ុយរ៉ូរៀបចំដីនេះសព្វគ្រប់ហើយ ក៏ខូចពេលវេលាធ្វើការនេះដោយយូរអង្វែងឆ្នាំដែរ ទើបរៀបចំបានសំរេចដូចបំណង ។

សេចក្តីដែលពោលមកនេះ គ្រាន់តែជាសេចក្តីពន្យល់ដោយទ្រួស ៗ ដើម្បីឲ្យមើលឃើញដំណើរទំនងផ្នែកដីនេះដោយសង្ខេប ។

១. ស.

# ពង្សាវតាររោម

(តទៅ)

ជនពួកនេះជាមនុស្សមានលក្ខណៈរឹងប៉ឹងម៉ឺងម៉ាត់អត់ធ្មត់កាន់របៀប កាន់សាសនាយ៉ាងតឹងរ៉ឹង ជឿស្តាប់បង្គាប់កាន់ច្បាប់ ។ ដោយលក្ខណៈនេះឯង ទើបធ្វើឲ្យពួករ៉ូម៉ាំងជាម្ចាស់លោកក្នុងសម័យគ្រានោះ ។

អំពីបឋមសម័យនៃពង្សាវតារក្រុងរោម — ពង្សាវតារក្រុងរោមក្នុងសម័យខាងដើមនោះ មិនសូវជាជាក់ច្បាស់ទេ អាស្រ័យអ្នកប្រាជ្ញរ៉ូម៉ាំងម្នាក់ឈ្មោះទីវ-លីវ (Tive-live) កាលក្នុងសតវត្សរ៍នៃព្រះបាទអូគុស្តុ (Auguste) ។ តែលោកនេះជាជាតិរ៉ូម៉ាំង ការសរសេរប្តែងពង្សាវតាររបស់ជាតិខ្លួនដោយប្រាសចាកអគតិនោះកម្រមានណាស់ ។ ឯសេចក្តីដែលលោកអ្នកប្រាជ្ញនេះបានតែងទុកនោះ មានទំនងជារឿងព្រេង ហួសវិស័យនឹងជឿប្រកាន់ជាសេចក្តីពិតបាន តែមានសេចក្តីពិត ដែលបានរកឃើញនៅទីទុកឆ្អឹងរបស់រ៉ូមុយលុសជាច្រើនដែរ ។ សេចក្តីអស់នោះធ្វើឲ្យយើងបានដឹងប្រវត្តិសាស្ត្ររបស់ក្រុងរោមក្នុងសម័យខាងដើមៗ នោះបែងចេញជាពីរសម័យ គឺសម័យមានស្តេចសោយរាជ្យ និងសម័យរេ-ពុយព្លិក ។

ក— សម័យមានក្សត្រគ្រងរាជ្យ — រ៉ូមុយលុសដែលយើងបានពោលមកហើយថា ជាអ្នកកសាងក្រុងរោមនោះមានរឿងក៏រពោលទុកយ៉ាងចំឡែកអស្ចារ្យ ដូចមានសេចក្តីថា បិតារបស់រ៉ូមុយលុសជាពូជអំបូរប្តូជាកូន

ផ្កាយព្រះពុធ មាតាជាពូជអំបូរផ្កាយព្រះព្រហស្បតិ៍ជាដើម ៗ សេចក្ដីអស់នេះនឹងជឿស្ដាប់ប្រកាន់ជាគតិពុំបាន តែមានសេចក្ដីល្មមស្ដាប់បានថា ក្នុងសម័យដែលកសាងក្រុងពេមហើយនោះ ពេមុយលុសត្រូវការឲ្យមនុស្សពីក្រៅចូលមកនៅក្រុងពេមច្រើនឡើង ទើបបើកឱកាសឲ្យពួកមនុស្សនៅដែនជិតខាង ចូលមកនៅបានឥតហាមឃាត់ មានប្រជាជនចូលមកនៅជាចំនួនច្រើន តែពួកដែលចូលមកនោះជាពួកអ្នកក្លាហាន មានតែពួកប្រុសៗមិនមានស្រីមកសោះឡើយ ៗ តមក គេបានចាត់ធ្វើពិធីបុណ្យមួយឡើង ហើយដឹកនាំឲ្យមនុស្សនៅខែត្រដែនសាប៊ាំង (Sabin) មកមើលបុណ្យ ៗ នៅឱកាសកំពុងធ្វើបុណ្យសម្ភោជនេះឯង ពួកអ្នកក្រុងពេមក៏ចូលទៅប្រឡូកដណ្ដើមយកកូនក្រមុំអ្នកសាប៊ាំងបានជាច្រើន ៗ ហេតុរំលោភរបស់ពួកពេម៉ាំងនេះនាំឲ្យកើតទៅជាទាស់ទែងយ៉ាងធំឡើង ទើបពួកសាប៊ាំងលើកគ្នាមកក្រុងពេម តែពួកស្ត្រីស្រុកសាប៊ាំងដែលក្លាយទៅជាពួកពេម៉ាំងហើយនោះ នាំគ្នាខំហាមឃាត់ទាំងពីរខាងមិនឲ្យច្បាំងកាប់សម្លាប់គ្នា តាំងអំពីនោះក៏ស្រុះស្រួលមូលមិត្តជាមួយគ្នានឹងពួកពេម៉ាំង ៗ ឯពេមុយលុសក៏ធ្វើជាស្ដេចសោយរាជ្យ ទ្រង់ចាត់រៀបចំឲ្យសេនាត៍ (Sénat សភាដំណាងកស្ត្រ) ជាបង្គោលយ៉ាងសំខាន់ក្នុងរៀបត្រួតត្រាស្រុក ៗ ក្សត្រអង្គនេះទិវង្គតទៅមុន ព. ស. ១៧២ ប្រាកដថា បាត់ខ្លួនទៅក្នុងខណៈមានខ្យល់ព្យុះធំ ៗ

ពួកកេម៉ាំងក្នុងជាន់នោះជឿថា កេមុយលុសជាព្រះឱរសរបស់ព្រះម្ចាស់សួគ៌ (គង់ត្រឡប់ទៀងទៅស្ថានសួគ៌វិញ) តែក្នុងសម័យនេះគេយល់ថា ប្រហែលជាកេមុយលុសត្រូវគេលួចសម្លាប់ហើយយកសពទៅលាក់ទុក ព្រោះមានសេចក្តីប្រាកដថា ក្នុងខណៈដែលកេមុយលុសធ្វើជាធំនោះបានធ្វើការមិនជាទីគាប់ចិត្តដល់ពួកមន្ត្រីក្នុងក្រុងកេមជាច្រើន ។

លុះកេមុយលុសទិវង្គតទៅហើយ មានអ្នកទទួលរាជ្យជាដំណតមកជាច្រើននាក់រហូតមកដល់ពុទ្ធសករាជ ៣៤ ទើបពួកពាហានបះបោរចលាចលឡើង បណ្តេញស្តេចចេញពីរាជបល្ល័ង្ក ។ ក្រុងកេមដែលធ្លាប់មានស្តេចសោយរាជ្យមកជាវេលាជិត២៤០ ឆ្នាំនោះ ក៏ផ្លាស់រាជការជាបែបរេពុយព្លិក តាំងអំពីព.ស. ៣៤ នោះជាដើមមក ។

១. សម័យរេពុយព្លិក — ប្រជាជនរបស់ក្រុងកេមបែងចេញជា ២ ពួក ហៅថា ពួកប៉ាទ្រីស៊ាំង១ពួក ប៉េបេអ៊ីយាំង១ពួក ។

បណ្តាជន២ពួកនេះ ពួកប៉ាទ្រីស៊ាំងមានសិទ្ធិអំណាច ជាពួកកេម៉ាំងដោយពិត ជាពួកមានអំណាចត្រួតត្រាស្រុកទេស ។ ឯពួកប៉េបេអ៊ីយាំងនោះ ជាពួកចូលមកនៅក្រោយឬជាពួកឈ្លើយ ដែលពួកកេម៉ាំងចាប់បានមក ឬជាពួកដែលមកនៅជ្រកកោនក្នុងគ្រួសាររបស់កេម៉ាំង ។ កាលណាត្រកូលដែលគេមកអាស្រ័យនោះមានលក្ខន្តិកៈមាំមួន ពួកដែលមកនៅជ្រកកោនក៏មានឋានៈជាពស្តុអ្នកស្រុកពិតប្រាកដឡើង តែ

កាលណាត្រកូលដែលខ្លួនមកអាស្រ័យនោះ សាបសូន្យទៅដោយហេតុណាមួយ ពួកនេះក៏ក្លាយទៅជាពួកប៉្លេបេអ៊ីយាន ។ មួយវិញទៀត ពួកខ្ញុំគេដែលបានរួចជាអ្នកជា ក៏មិនមានអំណាចធ្វើជាពួកប៉ាទ្រីស្យានដែរ តែងនៅជាប៉្លេបេអ៊ីយានដដែល ។

ពួកប៉្លេបេអ៊ីយានមានចំនួនច្រើន ហើយខ្លះជាអ្នកមានសម្បត្តិស្តុកស្តម្ភ អាចនឹងប្រើកម្លាំងកាយកំឡាំងទ្រព្យជួយជាកំឡាំងទ័ពរបស់ស្រុកទេសបាន ។ គង់សម័យដែលក្រុងរោមនៅមានក្សត្រគ្រងរាជ្យនោះព្រះបាទសែរវីយុស (Servius) ជាក្សត្រទី ៦ តមកអំពីរ៉ូមុយលុស ទ្រង់ចង់បានប្រយោជន៍អំពីពួកប៉្លេបេអ៊ីយាន ទើបបែងចាត់លំដាប់ថ្នាក់ប្រជាពស្ត្រឡើងជាថ្នាក់ឲ្យមានថ្នាក់ខ្ពស់នឹងថ្នាក់ទាប តាមចំនួនទ្រព្យសម្បត្តិ ។ ការចែកថ្នាក់តាមចំនួននេះ ពួកប៉្លេបេអ៊ីយានមានអំណាចចូលធ្វើជាទាហានបាន ។ គង់ពង្សាវតារក្រិក ដែលយើងបានមើលមកហើយក្តី ឬពង្សាវតាររោមដែលយើងកំពុងមើលនេះក្តី ការធ្វើជាទាហាននេះមិនមែនធ្វើបានទួទៅទេ តែងមានពូជអំបូរល្អឬជាមនុស្សជាន់ខ្ពស់ទើបមានអំណាចបានធ្វើជាទាហាន ។ គង់សម័យក្រុងរោមនេះ ពួកទាហានមានអំណាចនិយាយការផែនដីបានច្រើនជាងសម័យនេះ ពោលគឺពួកទាហានមានអំណាចដាច់ស្រេចថា ត្រូវធ្វើសង្គ្រាមឬមិនត្រូវធ្វើសង្គ្រាម ត្រូវច្បាំងនឹងអ្នកណា ឬនឹងស្ងប់សឹកសង្គ្រាមទៅវិញ ។ កិច្ចសំខាន់ៗអស់នេះទាហាន

ជាអ្នកវិនិច្ឆ័យសម្រេច ។ ទុកជាពួកប៉្លេបេអ៊ីយ៉ាន់បានចូលធ្វើជាទាហាន ហើយក៏ដោយ ក៏មានសិទ្ធិអំណាចត្រឹមប៉ុណ្ណឹងមិនមានអំណាចយ៉ាងដទៃទៀត ដូចជាកាលក្រុងរ៉ូមបានតាំងជារេពុយព្លិកឡើងហើយមានអ្នកគ្រប់គ្រងស្រុកដែលហៅថា កុងស៊ុល (Consuls) ដែលចាត់រើសតាំងឡើងក្នុងមួយដងៗមានចំនួនពីរនាក់ មានអំណាចនៅក្នុងដំណែងបាន ១ ឆ្នាំ មានអំណាចខ្ទង់មុខក្រសួងដូចជាប្រធានាធិបតីក្នុងសម័យនេះ ។ ប្រសិនបើជាវេលាដែលស្រុកទេសធ្លាក់ទៅក្នុងទីលំបាកតឹងចង្អៀតណាស់ ក៏ចាត់ការជ្រើសរើសតាំងអ្នកបញ្ជាការដែលមានអំណាចខ្ពង់ខ្ពស់បំផុតឡើងម្នាក់ ហៅថា ឌិកតាទ័រ (Dictateur) ហើយមានសមប៉្រេសេណាត់នៅប្រចាំសម្រាប់ស្រុកជានិច្ច មានសមាជិកប្រចាំនៅក្នុងសភានេះចំនួន ៣០០ នាក់ ។ ដំណែងកុងស៊ុលក្តី ឌិកតាទ័រក្តី សេណាត់ក្តី អ្នកដែលបានទទួលដំណែងអស់នេះសុទ្ធតែជាពួកប៉ាទ្រីស្យាំងទាំងអស់ ។ ពួកប៉្លេបេអ៊ីយ៉ាន់ មិនមានឱកាសចូលប្រចាំនៅក្នុងដំណែងអស់នេះឡើយ ។ ពួកប៉្លេបេអ៊ីយ៉ាន់ដែលទីទាល់ក្រផង ហើយបើត្រូវទៅចងការប្រាក់ពីពួកអ្នកមាន គេរមែងគិតយកការប្រាក់តាំងពី ១២ ដល់ ២៥ % ហើយម្ចាស់បំណុលក្នុងគ្រានោះ មានអំណាចយកកូនបំណុលទៅដាក់គុក ឬលក់ជាខ្ញុំគេក៏បានផង (ប្រសិនបើមិនសងបំណុល) ។

កាលបើពួកប៉ូបេអ៊ីយ៉ាន មានមុខក្រសួងត្រូវទំនុកបំរុងកងទ័ពដែរ តែមិនមានសិទ្ធិអំណាចស្មើនឹងពួកប៉ាទ្រីស៊ានដូច្នោះ ក៏មានចិត្តទោមនស្ស ជាពន្ទឹកជាយូរអង្វែងណាស់ ៗ មានប្រជាជនជាច្រើននាំគ្នាលើកគ្រួសារ ចេញពីក្រុងរោមទៅតាំងភូមិលំនៅលើភ្នំ ១ ដើម្បីកសាងស្រុកមួយជា សម្បត្តិរបស់ខ្លួនឡើង ៗ ហេតុកេទំនងនេះ រមែងក្លាយទៅជាភ័យ យ៉ាងធំក្រៃលែងសម្រាប់ក្រុងរោម ព្រោះខ្លួនបង់កំឡាំងមនុស្សនឹងកំឡាំង ទ្រព្យជាច្រើន ទើបសម្រេចសេណាត់ខំប្រឹងប្រែងចាត់ការសង្រួបសង្រួម ដោយស្រួសពន់ ហើយចាត់ការដំឡើងអំណាចពួកប៉ូបេអ៊ីយ៉ានបន្តិច ៗ ឡើងទៀត ៗ ការដែលពួកប៉ូបេអ៊ីយ៉ានខំព្យាយាមឲ្យបានសេចក្តីស្មើ ភាគនេះជាវេលា ១៣០ ឆ្នាំ គឺនៅក្នុងពុទ្ធសករាជ ១៧៧ ឆ្នាំ ទើបពួក ប៉ូបេអ៊ីយ៉ានមានសិទ្ធិអំណាចស្មើនឹងពួកប៉ាទ្រីស៊ាន ៗ តាំងអំពីនោះមក ឈ្មោះប៉ាទ្រីស៊ាននឹងប៉ូបេអ៊ីយ៉ានក៏លែងបាត់សូន្យទៅ គង់នៅតែឈ្មោះ ជា ពួករោម៉ាំង ដូចគ្នាទាំងអស់ ៗ

(មានត)

# រឿងបុរសម្នាក់ដេកលក់ក្នុងសាលា

មាននិទានមួយដំណាលថា មានបុរសម្នាក់ដេកលក់លើសាលា ហើយមានអាចោរម្នាក់លួចគោគេៗដេញទាក់ៗរត់ទៅកាន់សាលានោះ ឯបុរសនោះភ្ញាក់ឡើងឃើញអាចោរនោះហើយក៏ចុះទៅចាប់បាន លុះម្ចាស់គោតាមទៅទាន់ អាចោរស្រដីទៅនឹងម្ចាស់គោថា ចៅនេះឯងលួចគោអ្នកៗ ឯបុរសដេកលើសាលាថា ចៅឯងលួចគោគេអញចាប់បាន ម្តេចក៏ថាអញវិញៗ ឯម្ចាស់គោឃើញអ្នកទាំង២ប្រកែកគ្នាដូច្នោះ ទំងចាប់តែមួយខ្លាចក្រែងពុំមែនជាចោរ ទើបចាប់ទាំងពីរនាក់នាំទៅប្តឹងចៅក្រមៗជំនុំពិចារណាទៅ ឃើញថាមានពាក្យប្រកែកគ្នាទៅវិញទៅមកស្មើគ្នាពុំលើសម្ខាងៗឡើយ ចៅក្រមទំងជំនុំជំរះកាត់សេចក្តីនេះពុំបាន ទើបនាំសេចក្តីនេះឡើងក្រាបទូលសម្តេចព្រះមហាក្សត្រដោយដំណើរនោះ ទើបព្រះអង្គទ្រង់ព្រះចិន្តាពិចារណាហើយឲ្យយកចៅទាំងពីរនោះទៅចងឲ្យមូសខាំហើយឲ្យអមាត្យទៅចាំស្តាប់ពាក្យចៅទាំងពីរនោះៗ ឯបុរសដេកលើសាលានោះថា ព្រោះតែឯងលួចគោគេ បានជាគេចងអញឲ្យមូសខាំៗ ឯអាចោរថា អញលួចមែនតែគោឯការអ្វីនៅសុខៗក៏ចៅឯងចាប់អញ ព្រោះតែចៅចាប់អញ បានជាគេចាប់ចងទាំងអញផង បើចៅកុំចាប់អញប្រហែលជាគេមិនចាប់ចងដូច្នេះទេ ចៅនឹងបន្ទោស

នរណា ៗ ឯអមាត្យក៏កត់ដោយដំណើរពាក្យចៅទាំងពីរនោះ ហើយនាំឡើងក្រាបទូលសម្តេចព្រះមហាក្សត្រ ព្រះអង្គបង្គាប់ឲ្យពិន័យមួយជាបួន យកទ្រព្យដើមចេញហើយចែកជាក្រយាពិន័យនោះជាភាគបី ភាគមួយឲ្យបានចៅម្ចាស់គោ ភាគពីរឲ្យបានទៅចៅផេកលើសាលាដែលចាប់បានតួចោរនោះ ព្រោះតែបុរសនោះចាប់ជាប់ទើបម្ចាស់គោតាមទាន់ ហេតុនោះឲ្យបានក្រយាពិន័យភាគពីរដូច្នេះ ៗ សម្តេចព្រះមហាក្សត្រ ព្រះអង្គបង្គាប់សេចក្តីដូច្នេះនេះសឹងប្រកបដោយសុចរិតយុត្តិធម៌ ហើយនាំគ្នាក្រាបលាទៅផ្ទះអាត្មាទីទៃ ៗ ហោង ៗ

# សេចក្ដីជូនដំណឹង

ព្រះរាជបណ្ណាល័យសូមជូនដំណឹងដល់លោក-អ្នកទាំងឡាយថា គន្ថវិចារណ៍មេប្រែនេះ ព្រះរាជបណ្ណាល័យទើបនឹងបោះពុម្ពរឿងថ្មីៗ ចេញផ្សាយបំណាយដល់អ្នកត្រូវការដូចនេះ:

១ - ទឹកទន្លេសាប .............. ដំឡៃ ៦០ សេន

២ - ក្រុងសុភមិត្រខ្សែ ១ .............. — ៧០ "

៣ - ឯកសហស្រាត្រី ភាគ ៨ .............. — ២៥ "

៤ - ច្បាប់កេរ្ដិ៍កាល .............. — ១០ "

៥ - ច្បាប់កូនចៅ .............. — ១៥ "

សៀវភៅចាស់បោះពុម្ពឡើងវិញ គឺ:

១ - ព្រះត្រៃលក្ខណ៍នឹងសន្និតវត្ត .... ដំឡៃ ១៥ សេន

២ - សីលនិទ្ទេស .............. — ៧០ "

៣ - អរិយសច្ចកថា .............. — ៥០ "

សូមអញ្ជើញទៅជាវបាននៅព្រះរាជបណ្ណាល័យ ទីងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យ ។